GMAC
Garment Manufacturers Association in Cambodia

# សេចក្ដីអំពាវនាវដល់ម្ចាស់/នាយករោងចក្រសមាជិក

ដោយសារវិធានការបិទខ្ទប់របស់រាជរដ្ឋាភិបាល វិស័យកាត់ដេរសម្លៀកបំពាក់ ស្បែកជើង និងផលិតផលធ្វើដំណើរ ទទួលរងផលប៉ះពាល់យ៉ាងខ្លាំង។ រោងចក្រដែលរងផលប៉ះពាល់ ប្រឈមមុខនឹងការខាតបង់ផ្នែកហិរញ្ញវត្ថុធ្ងន់ធ្ងរ ខណៈកម្មករនិយោជិតរងគ្រោះក៏ប្រឈមមុខនឹងការថយចុះនូវប្រាក់ចំណូលដោយសារការព្យួរកិច្ចសន្យាការងារ។

តាមច្បាប់ស្ដីពីការងារនិងសេចក្ដីណែនាំលេខ០៤៣/២១ ក.ប/ស.ណ.ន.ខ.ល ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២១ របស់ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ កម្មករនិយោជិតមិនមានកាតព្វកិច្ចបំពេញការងារឱ្យនិយោជក ហើយនិយោជកមិនមានកាតព្វកិច្ចផ្ដល់ប្រាក់ឈ្នួលដល់កម្មករនិយោជិតក្នុងអំឡុងពេលព្យួរកិច្ចសន្យានេះ។

ទោះយ៉ាងណាក្ដី ដោយមើលឃើញភាពលំបាកដែលកម្មករនិយោជិតរបស់យើងកំពុងជួបប្រទះក្នុងអំឡុងពេលដ៏លំបាកនេះ សមាគមសូមអំពាវនាវដល់សមាជិកទាំងអស់ដែលស្ថិតនៅក្នុងតំបន់បិទខ្ទប់ពិចារណាផ្ដល់ប្រាក់ឧបត្ថម្ភក្នុងចំនួនណាមួយដល់កម្មករនិយោជិតរបស់លោក លោកស្រី។ ប្រាក់ឧបត្ថម្ភនេះគឺដើម្បីជួយបន្ថែមពីលើការឧបត្ថម្ភផ្សេងៗ ដែលផ្ដល់ដោយរាជរដ្ឋាភិបាលក្នុងការជួយសម្រួលជីវភាពប្រចាំថ្ងៃរបស់កម្មករនិយោជិតរហូតដល់ការបិទខ្ទប់ត្រូវបានបញ្ចប់។

សមាគមសូមកោតសរសើរជាមុនចំពោះកាយវិការ និងទឹកចិត្តមនុស្សធម៌ក្នុងការជួយកម្មករនិយោជិតរងគ្រោះទាំងអស់។ សមាគមសង្ឃឹមថា ស្ថានភាពនឹងត្រឡប់ទៅរកភាពដូចធម្មតាវិញនាពេលឆាប់ៗ ហើយរោងចក្រនិងកម្មករនិយោជិតអាចត្រឡប់ចូលធ្វើការវិញ។

សូមអរគុណ!

រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ មេសា ឆ្នាំ ២០២១

**សមាគមរោងចក្រកាត់ដេរនៅកម្ពុជា**

ព្រះរាជាណាចក្រកម្ពុជា
GARMENT MANUFACTURERS ASSOCIATION IN CAMBODIA
សមាគមរោងចក្រកាត់ដេរនៅកម្ពុជា

 សមាគមរោងចក្រកាត់ដេរនៅកម្ពុជា Garment Manufacturers Association in Cambodia

តំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ ភូមិត្រពាំងគល់ សង្កាត់កន្ទោក ខណ្ឌកំបូល រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
Phnom Penh Special Economic Zone, Phum Trapeang Kul, Sangkat Kantouk, Khan Kambol, Phnom Penh, Cambodia.
Tel: (855)-23-301 181 | E-mail: info@gmac-cambodia.org | Website: www.gmac-cambodia.org